# អគ្គនាយកដ្ឋានថវិកា

# បទបង្ហាញស្ដីពី
# ប្រព័ន្ធថវិកានៅកម្ពុជា

# មាតិកា

ផ្នែកទី ១. វឌ្ឍនភាពនៃការកែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា

ផ្នែកទី ២. ផែនការយុទ្ធសាស្ត្រថវិកា

ផ្នែកទី ៣. ថវិកាកម្មវិធី

ផ្នែកទី ៤. អង្គភាពថវិកា

ផ្នែកទី ៥. នីតិវិធីអនុវត្តថវិកាចរន្តតាមកម្មវិធី

# ផ្នែកទី ១. វឌ្ឍនភាពនៃការកែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា

មហិច្ឆតា និងការផ្លាស់ប្តូរជាបណ្តើរៗ នូវប្រព័ន្ធគ្រប់គ្រងថវិការបស់កម្ពុជា ឆ្ពោះទៅប្រព័ន្ធគ្រប់គ្រងថវិកាផ្តោតលើលទ្ធផល ឬ សមិទ្ធកម្ម និងវិមជ្ឈការ ឱ្យបានជោគជ័យនៅឆ្នាំ២០២៥។

# ១.១. ក្របខណ្ឌ និង វឌ្ឍនភាពនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## អភិក្រម: ៤ ដំណាក់កាល ក្នុង ៤ ជំហាន

PFM Reform Program

- ដំណាក់កាលទី ១ (2005 – 2008)

ជំហានទី ១: ភាពជឿទុកចិត្តនៃថវិកា

- ដំណាក់កាលទី ២ (2009 – 2015)

ជំហានទី ២: គណនេយ្យភាពហិរញ្ញវត្ថុ

ជំហានទី ៣: ការផ្សារភ្ជាប់ថវិកាទៅនឹងគោល-នយោបាយ

- ដំណាក់កាលទី ៣ (2016 – 2020)

ជំហានទី ៤: គណនេយ្យភាពចំពោះសមិទ្ធកម្ម

- ដំណាក់កាលទី ៤ (2020 – 2025)

# ១.២. ការត្រៀមលក្ខណៈសម្រាប់ដំណាក់កាលទី ៣ នៃ PFM ចាប់ពីឆ្នាំ ២០០៥

1. រៀបចំក្របខណ្ឌ និងគោលការណ៍ណែនាំសម្រាប់អនុវត្តសាកល្បងថវិកាកម្មវិធី (PB)
2. ធ្វើវិសោធនកម្មច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈក្នុងឆ្នាំ 2008 ដើម្បីផ្លាស់ប្តូរវដ្តថវិកា និងការអនុវត្តសាកល្បង PB
   - ផែនការយុទ្ធសាស្រ្តថវិកា (BSP) ត្រូវបានអនុវត្តចាប់ពីឆ្នាំ 2008
     - ➢ គោលការណ៍ណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្រ្តថវិកា
   - ដាក់ក្រសួងចំនួន ៨ ឱ្យអនុវត្តសាកល្បងថវិកាកម្មវិធីដោយផ្នែក (2008-2014)
3. របាយការណ៍វាយតំលៃលើការអនុវត្ត PB ក្នុងឆ្នាំ 2012 និងកំណត់ទិសដៅសម្រាប់ 2013-2020
4. រៀបចំក្របខណ្ឌ និង គោលការណ៍ណែនាំ សម្រាប់ការដាក់អនុវត្តអង្គភាពថវិកា (BE) នៅឆ្នាំ 2013
5. ដាក់អនុវត្តសាកល្បងថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកា ក្នុងឆ្នាំ 2015 (១០ ក្រសួង ស្ថាប័ន), និង ឆ្នាំ 2016 (១៥ ក្រសួង ស្ថាប័ន),
   - គោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី ត្រូវបានរៀបចំ និង ដាក់អនុវត្តចាប់ពីឆ្នាំ 2015

# ១.៣. ការវិវត្តន៍នៃប្រព័ន្ធថវិកា



# ១.៤. ទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា 2013-2020

គោលដៅគន្លឹះ ២ នៃការកែទម្រង់ប្រព័ន្ធថវិកា ២០២០

- បង្កើនវិន័យក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (តុល្យភាព/ចីរភាព) បង្កើនប្រសិទ្ធភាពវិភាជ (វិភាជចំគោលដៅអាទិភាព) និងបង្កើនប្រសិទ្ធភាពបច្ចេកទេស និងប្រតិបត្តិការចំណាយ។
- ការផ្លាស់ប្តូរជាបណ្តើរៗ ពីប្រព័ន្ធថវិកាផ្តោតលើធាតុចូល និងមជ្ឈការ ទៅប្រព័ន្ធថវិកា និងការគ្រប់គ្រងដែលផ្តោតលើធាតុចេញ (លទ្ធផល / សមិទ្ធកម្ម) និងមានលក្ខណៈវិសហមជ្ឈការ និងវិមជ្ឈការសមស្រប។

# ១.៥. ទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា 2013-2020 (ត)

**លក្ខណៈនៃប្រព័ន្ធថវិកាកម្ពុជា**

**១-ការរៀបចំថវិកា:** ត្រូវផ្អែកលើគោលនយោបាយ កម្មវិធី និងសូចនាករ ដែលមានក្របខ័ណ្ឌគតិយុត្ត និងយន្តការច្បាស់លាស់ក្នុងការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និងអាចវាស់វែងលទ្ធផល ដើម្បីធានាវិន័យថវិកា (តុល្យភាព/ និរន្តភាព) ប្រសិទ្ធភាពវិភាជ (វិភាជចំគោលដៅអាទិភាព) និងប្រសិទ្ធភាពបច្ចេកទេស និងប្រតិបត្តិការចំណាយ។

**២-ការអនុម័តថវិកា:** ប្រភេទ ជំពូកចំណាយ គោលនយោបាយ កម្មវិធី និងសូចនាករ។

**៣-ការអនុវត្តថវិកា:** ធានាឱ្យមានការអនុវត្តថវិកាប្រកបដោយស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាព ត្រួតពិនិត្យ តាមដាន និងវាយតម្លៃទាំងលើធាតុចូល និង ធាតុចេញ។

**៤-ការត្រួតពិនិត្យនិងវាយតម្លៃលើ លទ្ធផល/សមិទ្ធកម្ម**

អនុវត្តក្របខណ្ឌ និងយន្តការតាមដានវាយតម្លៃលទ្ធផល និងការគ្រប់គ្រងផ្តោតលើធាតុចេញ ស្របតាមទិសដៅ វិសហមជ្ឈការ/វិមជ្ឈការ ដើម្បីធានាតម្លាភាព គណនេយ្យភាព និងការទទួលខុសត្រូវច្បាស់លាស់

# ១.៦. ទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា 2013-2020 (ត)

## យុទ្ធសាស្ត្រសម្រាប់ពង្រឹងការអនុវត្តប្រព័ន្ធថវិកាថ្មី ដោយផ្អែកលើលទ្ធផល



**១. ការពង្រឹងការរៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្រថវិកា** (BSP)

ដើម្បីប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកា ទៅនឹងគោលនយោបាយ

**២. ការពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធីពេញលេញ** (PB)

ដើម្បីប្រសិទ្ធភាពនៃលទ្ធផល/ សមិទ្ធកម្ម

**៣. ពង្រឹង និង ពង្រីកការអនុវត្តអង្គភាពថវិកា** (BE)

ដើម្បីបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ និងការទទួលខុសត្រូវលើលទ្ធផលការងារ

**៤. ពង្រឹង និងពង្រីកការអនុវត្តចំណាត់ថ្នាក់មាតិកាថវិកាថ្មី, ប្លង់គណនីថ្មី និង** FMIS

ដើម្បីពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ

# ១.៧. យុទ្ធសាស្ត្រនៃការពង្រឹង និង ពង្រីកថវិកាកម្មវិធី

1. ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០០៨ ÷ មាត្រា ២៥ ការដាក់អនុវត្តថវិកាកម្មវិធី ដោយប្រកាសរបស់ កសហវ
2. យុទ្ធសាស្ត្រនៃការពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធី តាមការសម្រេចរបស់ប្រមុខរាជរដ្ឋាភិបាល
   - ឆ្នាំ 2015 ចំនួន ១០ ក្រសួង ស្ថាប័ន ព្រមទាំង មន្ទីរជំនាញរាជធានី ខេត្ត,
   - ឆ្នាំ 2016 ចំនួន ១៥ ក្រសួង ស្ថាប័ន ព្រមទាំង មន្ទីរជំនាញរាជធានី ខេត្ត ,
   - ឆ្នាំ 2017 ចំនួន ១១ ក្រសួង ស្ថាប័ន ព្រមទាំង មន្ទីរជំនាញរាជធានី ខេត្ត, និង សាលាខេត្តមួយចំនួន
   - ឆ្នាំ 2018 ចំនួន ៣ ក្រសួង ស្ថាប័ន, និង សាលាខេត្តមួយចំនួនបន្ថែមទៀត
   - តាមការគ្រោងទុកបឋម គឺនៅ ឆ្នាំ ២០២០ គឺ គ្រប់ស្ថាប័ន ទាំងថ្នាក់ជាតិ និង រដ្ឋបាលថ្នាក់ក្រោមជាតិ អនុវត្តថវិកាកម្មវិធីពេញលេញ  ដើម្បីឈានទៅអនុម័តថវិកា តាមកម្មវិធី

# ១.៨. ការផ្លាស់ប្តូរមូលដ្ឋាននៃការរៀបចំថវិកា និងអនុម័តថវិកា

| មូលដ្ឋានបច្ចុប្បន្ន | | មូលដ្ឋានថ្មី | | |
|---|---|---|---|---|
| **ប្រភេទ/ជំពូក** | **តម្រូវការថវិកា (លានរៀល)** | **គោលនយោបាយ** | **សូចនាករ/គោលដៅ** | **តម្រូវការថវិកា (លានរៀល)** |
| ប្រភេទ ១ | ១០០ ០០០ | (១) គោលនយោបាយទី១ | សូចនាករទី១÷<br>សូចនាករទី២÷ | ៩៤ ០០០ |
| ៦០ | ៤១ ០០០ | *១.១- កម្មវិធីទី ១* | សូចនាករទី១÷<br>សូចនាករទី២÷ | ៤៧ ០០០ |
| ៦១ | ១៤ ០០០ | ១.១.១- អនុកម្មវិធី | | |
| ៦២ | ១៣ ០០០ | ១.១.១.១- ចង្កោមសកម្មភាព | | |
| ៦៤ | ៣២ ០០០ | ១.២- កម្មវិធីទី ២ | សូចនាករទី១÷<br>សូចនាករទី២÷ | ៤៧ ០០០ |
| ប្រភេទ ២ | | ១.២.១- អនុកម្មវិធី | | |
| ៦៦ | | ១.២.១.១- ចង្កោមសកម្មភាព | | |
| ប្រភេទ ៣ | ២២ ០០០ | (២) គោលនយោបាយទី២ | សូចនាករទី១÷<br>សូចនាករទី២÷<br>សូចនាករទី៣÷ | ១៤១ ០០០ |
| ៦៥ | ២២ ០០០ | *២.១- កម្មវិធីទី ៣* | សូចនាករទី១÷<br>សូចនាករទី២÷ | ៤៧ ០០០ |
| ប្រភេទ ៤ | ១១៣ ០០០ | ២.១.១- អនុកម្មវិធី | | |
| ៦៣ | ១១៣ ០០០ | ២.១.១.១- ចង្កោមសកម្មភាព | | |
| | | *២.២- កម្មវិធីទី ៤* | សូចនាករទី១÷<br>សូចនាករទី២÷ | ៤៧ ០០០ |
| | | ២.២.១- អនុកម្មវិធី | | |
| | | ២.២.១.១- ចង្កោមសកម្មភាព | | |
| | | *២.៣- កម្មវិធីទី ៥* | សូចនាករទី១÷<br>សូចនាករទី២÷ | ៤៧ ០០០ |
| | | ២.៣.១- អនុកម្មវិធី | | |
| | | ២.៣.១.១- ចង្កោមសកម្មភាព | | |
| **សរុប** | **២៣៥ ០០០** | **គោលនយោបាយ២/កម្មវិធី៥** | **សូចនាករ ៥/១០** | **២៣៥ ០០០** |

# ទិដ្ឋភាពរួមនៃ ប្រព័ន្ធថវិកាប្រទេសកម្ពុជា បច្ចុប្បន្ន

មហិច្ចតា និងការផ្លាស់ប្ដូរជាបណ្ដើរៗ
នូវប្រព័ន្ធគ្រប់គ្រងថវិការបស់កម្ពុជា
ឆ្ពោះទៅប្រព័ន្ធគ្រប់គ្រងថវិកាផ្ដោតលើ
លទ្ធផល ឬ សមិទ្ធកម្ម និងវិមជ្ឈការ
នៅឆ្នាំ២០២៥។

# ១.៩. ដំណើរការនៃការរៀបចំ និង អនុវត្តថវិកាប្រចាំឆ្នាំ

## ឆ្នាំថវិកា របស់ប្រទេសកម្ពុជាបានចាប់ផ្តើមពី ថ្ងៃទី ១ ខែ មករា ដល់ថ្ងៃទី ៣១ ខែធ្នូ



# ១.១០. ក្របខណ្ឌ និង ប្រតិទិននៃការរៀបចំថវិកាប្រចាំឆ្នាំ

**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ / កម្មវិធីវិនិយោគសាធារណៈ**

**អគ្គ.គោលនយោបាយ / ក.ស.ហ.វ**

- ថវិកាប្រចាំឆ្នាំ
- ព្យាករណ៍សេដ្ឋកិច្ច
- ព្យាករណ៍ចំណូល

ក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច & ក្របខណ្ឌថវិការយៈពេលមធ្យម

វេទិកាពិគ្រោះយោបល់ជាសាធារណៈ
(សមាជិកសភា, អង្គការក្រៅរដ្ឋាភិបាល, ដៃគូអភិវឌ្ឍន៍, វិស័យឯកជន)

**ការប៉ាន់ប្រមាណការចំណាយ**

**អគ្គ.ថវិកា / ក.ស.ហ.វ**

ផែនការយុទ្ធសាស្ត្រថវិកា

សារាចរណែនាំការរៀបចំថវិកា

សំណើរសុំថវិការបស់ក្រសួង

- ការចរចាថវិកា
- ការបូកសរុបថវិកា

**អនុម័តដោយគណៈរដ្ឋមន្ត្រី**

របាយការណ៍សេដ្ឋកិច្ច

ច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុប្រចាំឆ្នាំ

អនុម័តដោយនីតិបញ្ញត្តិ

ព្រះរាជានុញ្ញាតឱ្យប្រើច្បាប់គ្រប់គ្រងហិរញ្ញវត្ថុប្រចាំឆ្នាំ

គ្រប់ក្រសួង ស្ថាប័នយកច្បាប់នេះទៅអនុវត្ត

- មីនា
- មេសា
- មិថុនា
- កក្កដា
- សីហា - កញ្ញា
- តុលា
- វិច្ឆិកា
- ធ្នូ
- មករា

# ១.១១. ទំនាក់ទំនងរវាងគោលនយោបាយ និង រចនាសម្ព័ន្ធកម្មវិធី



# ១.១២. ទំនាក់ទំនងរវាងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន និងរចនាសម្ព័ន្ធគោលនយោបាយ

| រចនាសម្ព័ន្ធគ្រប់គ្រង | សិទ្ធិអំណាច និងការទទួលខុសត្រូវ | រចនាសម្ព័ន្ធគោលនយោបាយ |
|---|---|---|
| កម្រិតដឹកនាំ និងកំណត់គោលនយោបាយ (កម្រិតទី១: ក្រសួងស្ថាប័ន) | កំណត់គោលនយោបាយ | គោលបំណងគោលនយោបាយ/ យុទ្ធសាស្ត្រ/កម្មវិធី |
| កម្រិតគ្រប់គ្រងបច្ចេកទេស និងកំណត់ យុទ្ធសាស្ត្រ/កម្មវិធី (កម្រិតទី២: អគ្គលេខាធិការ/អគ្គនាយកដ្ឋាន) | កំណត់យុទ្ធសាស្ត្រ/ កម្មវិធី | យុទ្ធសាស្ត្រ/កម្មវិធី |
| កម្រិតបច្ចេកទេស និងកំណត់ អនុកម្មវិធី/ ចង្កោមសកម្មភាព (កម្រិតទី៣: នាយកដ្ឋាន / សមមូល) | កំណត់អនុកម្មវិធី/ ចង្កោមសកម្មភាព | អនុកម្មវិធី/ ចង្កោមសកម្មភាព |
| កម្រិតបច្ចេកទេស និងអនុវត្តសកម្មភាព (កម្រិតទី៣/៥...: បណ្ដាអង្គភាពក្រោមឱវាទ) | កំណត់/អនុវត្តសកម្មភាព | សកម្មភាព |

# ១.១៣. ធាតុ និង លក្ខណៈរបស់ថវិកាកម្ពុជា

ចំណាយប្រតិបត្តិការ + ចំណាយមូលធន = ថវិកា

**ចំណាយប្រតិបត្តិការ**
- ចំណាយប្រចាំ
- ចំណាយសម្រាប់គោលនយោបាយថ្មី
- ចំណាយដែលកើតឡើងតែម្តង-មិនប្រចាំ

**ចំណាយមូលធន**
- ហិរញ្ញប្បទានក្នុងស្រុក
- ទ្រទ្រង់ថវិកា
- ហិរញ្ញប្បទានឥតសំណង & ឥណទានសម្បទាន

## លក្ខណៈពិសេសនៃថវិកា

ថវិកាប្រចាំឆ្នាំ៖ មានរយៈពេល ១២ ខែ គឺចាប់ផ្តើមពីថ្ងៃទី ១ ខែ មករា ដល់ថ្ងៃទី ៣១ ខែធ្នូ

ឥណទានចំណាយក្នុងឆ្នាំនេះ មិនអនុញ្ញាត ឱ្យលើកទៅចាយនៅឆ្នាំបន្ទាប់

ខ្ទង់ចំណាយដែលអនុញ្ញាតឱ្យលើកទៅចាយនៅឆ្នាំបន្ទាប់ គឺមានតែរាល់ចំណាយលើគម្រោងអភិវឌ្ឍទាំងឡាយណាដែលជាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍

រាល់គម្រោងវិនិយោគ ត្រូវបានវាយតំលៃ និងអនុញ្ញាតដោយប្រមុខរាជរដ្ឋាភិបាល

## គោលការណ៍ណែនាំ

- ✓ គោលការណែនាំ សម្រាប់ BSP
- ✓ គោលការណែនាំ សម្រាប់ PB
- ✓ គោលការណែនាំ សម្រាប់ BE

# ១.១៤. ជំហានបន្ទាប់ ÷

- ❖ រៀបចំយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៧ - ២០២៥ លើមូលដ្ឋាន ÷
  - ✓ បទពិសោធន៍នៃការអនុវត្ត ២ ឆ្នាំ មកនេះ
  - ✓ ទស្សនកិច្ចសិក្សាថ្មីៗ នៅ ប្រទេសម៉ាឡេស៊ី និង ប្រទេសថៃ
- ❖ កំណត់ផែនទីគោលចរសម្រាប់អនុវត្ត
  - ✓ ការធ្វើវិសោធនកម្មច្បាប់ប្រព័ន្ធហិរញ្ញវត្ថុដោយផ្នែក ឬ ការរៀបចំច្បាប់ប្រព័ន្ធថ្មី
  - ✓ ការដាក់អនុវត្តក្របខណ្ឌថវិការយៈពេលមធ្យមសម្រាប់វិស័យ និង ក្រសួងនីមួយៗ
  - ✓ ការកំណត់ពិដានកញ្ចប់ថវិកាប្រចាំឆ្នាំ
  - ✓ ការដាក់អនុវត្តប្រព័ន្ធត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្ត (M&E)
- ❖ ធានាប្រសិទ្ធភាពនៃភាពប្រទាក់ក្រឡារវាងការកែទម្រង់ប្រព័ន្ធថវិកា ជាមួយនឹង ការកែទម្រង់រដ្ឋបាលសាធារណៈ និងការកែទម្រង់បៀវត្ស
- ❖ ធានាប្រសិទ្ធភាពនៃភាពប្រទាក់ក្រឡារវាងការកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ក្នុងក្របខណ្ឌវិមជ្ឈការ និង វិសហមជ្ឈការ (D&D)


ពតិមាន
ថវិកា
លទ្ធផល
ក្នុងឆ្នាំ


ពតិមានគ្រប់គ្រាន់ សាមញ្ញងាយយល់
ថវិកា
លទ្ធផលក្នុងឆ្នាំ

# ផ្នែកទី ២. ផែនការយុទ្ធសាស្ត្រថវិកា

មហិច្ឆតា និងការផ្លាស់ប្តូរជាបណ្តើរៗ នូវប្រព័ន្ធគ្រប់គ្រងថវិការបស់កម្ពុជា ឆ្ពោះទៅប្រព័ន្ធគ្រប់គ្រងថវិកាផ្តោតលើលទ្ធផល ឬ សមិទ្ធកម្ម និងវិមជ្ឈការ ឱ្យបានជោគជ័យនៅឆ្នាំ២០២៥។

# ២.១. សេចក្តីផ្តើម

- ប្រព័ន្ធថវិកាតាមបន្ទាត់ថវិកា (Line Item Budgeting)
  - កញ្ចប់ថវិកាឆ្នាំបន្ទាប់ ផ្អែកលើកំណើនឆ្នាំចាស់, មិនមានមូលដ្ឋានច្បាស់លាស់ , មិនបង្ហាញពីគោលដៅច្បាស់លាស់នៃតម្រូវការចំណាយ
  - មិនបង្ហាញការផ្សារភ្ជាប់ថវិកា ទៅគោលនយោបាយ
  - ធនធានហិរញ្ញវត្ថុដែលមានទាំងអស់មិនឆ្លុះបញ្ចាំង គឺ មិនសមាហរណកម្ម
- ក្នុងក្របខណ្ឌ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ផែនការយុទ្ធសាស្ត្រថវិកា ត្រូវបានបង្កើតជាឧបករណ៍ដើម្បីផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលនោះ គឺ

ការធ្វើផែនការ ⟷ ការធ្វើថវិកា

# ២.១. សេចក្ដីផ្ដើម (ត)

**01 ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា**
ពីខែ មីនា ដល់ ខែឧសភា

**02 ការរៀបចំកញ្ចប់ថវិកា**
ពីខែ មិថុនា ដល់ ខែកញ្ញា

**03 ការអនុម័តថវិកា**
ពីខែតុលា ដល់ ខែធ្នូ

- មាត្រា ៣៩ នៃច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ បានកំណត់នូវប្រតិទិនសម្រាប់ការរៀបចំថវិកា (រៀបចំសេចក្ដីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ) ជា ០៣ ដំណាក់កាល៖

# ២.២. និយមន័យ

## ផែនការយុទ្ធសាស្ត្រថវិកា

ជាផែនការថវិការយៈពេលមធ្យម (៣ ឆ្នាំ រំកិល) តាមអភិក្រមពីក្រោមឡើងលើ (Bottom-Up Approach) ដើម្បីធានាថា គោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ត្រូវបានផ្សារភ្ជាប់ទៅនឹងថវិកា តាមរយៈការកំណត់ឱ្យបានច្បាស់លាស់នូវ ÷

- គោលបំណងគោលនយោបាយរបស់ ក្រសួង ស្ថាប័ន
- កម្មវិធី ឬ យុទ្ធសាស្ត្រអាទិភាព
- សូចនាករ និងគោលដៅសូចនាករ
- ធនធានចរន្ត និងធនធានមូលធន ទាំងថវិការដ្ឋ ទាំងថវិកាដៃគូអភិវឌ្ឍន៍

# ២.៣. ទំនាក់ទំនងរវាងគោលនយោបាយ និង រចនាសម្ព័ន្ធកម្មវិធី

- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និង គោលនយោបាយតាមវិស័យ (កម្រិតជាតិ)
  - គោលបំណងគោលនយោបាយ (កម្រិតក្រសួង)
    - កម្មវិធី (យុទ្ធសាស្ត្រកម្រិតក្រសួង)
      - អនុកម្មវិធី
        - ចង្កោមសកម្មភាព
        - ចង្កោមសកម្មភាព
      - អនុកម្មវិធី
        - ចង្កោមសកម្មភាព
        - ចង្កោមសកម្មភាព

# ២.៤. ដំណើរការនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា

1
**ជំហានទី ១**
*កំណត់គោលបំណងគោលនយោបាយ*

2
**ជំហានទី ២**
*រៀបចំកម្មវិធី ឬ យុទ្ធសាស្ត្រអាទិភាព*

3
**ជំហានទី ៣**
*កំណត់សូចនាករ និងគោលដៅសូចនាករ*

4
**ជំហានទី ៤**
*ការកំណត់ធនធាន*

# ២.៥. អត្ថប្រយោជន៍នៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា




1. ផ្សារភ្ជាប់ថវិកាទៅនឹងគោលបំណងគោលនយោបាយ
2. មូលដ្ឋានសម្រាប់ការរៀបចំយុទ្ធសាស្ត្រអាទិភាព
3. មូលដ្ឋាននៃការរៀបចំថវិកាកម្មវិធី
4. ធានាបានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃការប្រើប្រាស់ធនធានសាធារណៈ
5. ឧបករណ៍សម្រាប់ធ្វើសមាហរណកម្មថវិការវាងថវិកាចរន្ត និងថវិកាមូលធន (ទាំងថវិការដ្ឋ និងថវិកាដៃគូអភិវឌ្ឍន៍)

# ផ្នែកទី ៣. ថវិកាកម្មវិធី

មហិច្ឆតា និងការផ្លាស់ប្តូរជាបណ្តើរៗ
នូវប្រព័ន្ធគ្រប់គ្រងថវិការបស់កម្ពុជា
ឆ្ពោះទៅប្រព័ន្ធគ្រប់គ្រងថវិកាផ្តោតលើ
លទ្ធផល ឬ សមិទ្ធកម្ម និងវិមជ្ឈការ
ឱ្យបានជោគជ័យនៅឆ្នាំ២០២៥។









# ៣.១. អត្ថប្រយោជន៍នៃថវិកាកម្មវិធី

1. ពង្រឹងការផ្សារភ្ជាប់ថវិកា ទៅនឹងគោលនយោបាយអាទិភាពរបស់ក្រសួង-ស្ថាប័ន

2. បង្កើតបន្ទាត់គណនេយ្យភាព (line accountability) ផ្ទៃក្នុងក្រសួង-ស្ថាប័ន រវាងថ្នាក់ដឹកនាំ និង អ្នកប្រតិបត្តិ/អង្គភាពប្រតិបត្តិ / **អង្គភាពថវិកា** (Budget Entity)

3. ព័ត៌មានប្រសើរជាងមុនអំពីគោលបំណងនៃតម្រូវការចំណាយ ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងដំណើរការនៃការធ្វើ **សេចក្ដីសម្រេចចិត្ត** (Decision Making Process) ក្នុងការវិភាជធនធាន/ថវិកា

4. ផ្លាស់ប្ដូរពីការយកចិត្តទុកដាក់តែលើ**ធាតុចូល** (Input) ទៅជាការផ្ដោតទៅលើលទ្ធផល (Output) ឬ សមិទ្ធកម្ម (Performance) របស់ក្រសួង ស្ថាប័ន នីមួយៗ

5. ជំរុញការប្រើប្រាស់ការវិភាគអត្ថប្រយោជន៍នៃថ្លៃចំណាយ (Cost-Benefit Analysis) ដើម្បីធានាតម្លៃនៃលុយ (Value for Money) ពោលគឺ ថ្លៃសមរម្យ ចំគោលដៅ ហើយទទួលបានបរិមាណច្រើន និង មានគុណភាព



# ៣.២. និយមន័យនៃថវិកាកម្មវិធី

## ថវិកាកម្មវិធី

- ជាការរៀបចំថវិកាដោយផ្អែកលើកម្មវិធីច្បាស់លាស់ ដើម្បីឈានទៅសម្រេចគោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន ស្របតាមគោលនយោបាយដែលមានចែងក្នុងវិស័យនីមួយៗ
- ត្រូវមានសូចនាករសមិទ្ធកម្មសម្រាប់ជាយន្តការតាមដាន ដើម្បីវាស់វែង ធ្វើរបាយការណ៍លទ្ធផលក្នុងឆ្នាំ (Ouput) និងលទ្ធផលចុងក្រោយ (Outcome) ទៅតាមកម្មវិធីនីមួយៗ ព្រមជាមួយតម្រូវការកំណត់ឱ្យបានច្បាស់លាស់នូវថ្លៃធាតុចូល (Input) ដែលរួមមាន ចំណាយចរន្ត និង ចំណាយមូលធនសម្រាប់អនុវត្តសកម្មភាព/ កម្មវិធី, គម្រោង

# ទិដ្ឋភាពទាំងមូលរបស់ថវិកាកម្មវិធី







កំណើនអត្រាអក្ខរកម្ម
កាត់បន្ថយអត្រាមរណភាពទារក
កាត់បន្ថយភាពក្រីក្ររបស់កសិករ

# Program Logic Model

Input → Output → Outcome

**ធាតុចូល**

- ធនធានមនុស្ស
- ធនធានហិរញ្ញវត្ថុ
- ឧបករណ៍និងសម្ភារៈបរិក្ខាផ្សេងៗ

**លទ្ធផលក្នុងឆ្នាំ**

- កម្មវិធីបណ្ដុះបណ្ដាល
- អ្នកជំងឺដែលទទួលការព្យាបាល
- លិខិតឆ្លងដែនដែលចេញ
- ការកសាងសាលារៀន និងមណ្ឌលសុខភាព

**លទ្ធផលចុងក្រោយ**

- ការកើនឡើងចំណេះដឹងឬជំនាញ
- សុខភាពប្រសើរឡើង
- ធ្វើឱ្យប្រសើរឡើងនូវពិន្ទុរបស់សិស្ស

# ៣.៣. ដំណើរការនៃការរៀបចំថវិកាកម្មវិធី



# ៣.៣.១. ការកំណត់គោលបំណងគោលនយោបាយ






# ៣.៣.២. ការកំណត់រចនាសម្ព័ន្ធកម្មវិធី







*** ក្រសួងមួយអាចកំណត់គោលបំណងគោលនយោបាយយ៉ាងច្រើនត្រឹម ២ និងកម្មវិធីយ៉ាងច្រើនត្រឹម ៥

# ៣.៣.៣. ការកំណត់សូចនាករ និងគោលដៅសូចនាករ






# ៣.៣.៣. ការកំណត់សូចនាករ និងគោលដៅសូចនាករ (ត)

## សូចនាករ

សូចនាករ គឺជារង្វាស់លើលទ្ធផលដែលសម្រេចបាន

ចែកចេញជា ២ កម្រិត÷

– **សូចនាករលទ្ធផលក្នុងឆ្នាំ** (Output Indicator)

– **សូចនាករលទ្ធផលចុងក្រោយ** (Outcome Indicator)

**សូចនាករលទ្ធផលក្នុងឆ្នាំ** វាស់វែងទៅលើទំនិញ ឬ សេវា ដែលផលិតបាន។

ឧទាហរណ៍ ចំនួន វ៉ាក់សាំង ដែលបានផ្តល់, ចំនួនពូជស្រូវដែលបានចែកជូនកសិករ

**សូចនាករលទ្ធផលចុងក្រោយ** វាស់វែងភាពសក្តិសិទ្ធិនៃលទ្ធផលចុងក្រោយ ដោយផ្អែកលើ មូលដ្ឋាននៃលទ្ធផលក្នុងឆ្នាំដែលសម្រេចបាន។

ឧទាហរណ៍ ភាគរយនិស្សិតទទួលបាន អាហារូបករណ៍, ភាគរយអ្នកជំងឺដែលជាសះស្បើយ

## ប្រភេទសូចនាករ

ប្រភេទនៃសូចនាករ÷

- **សូចនាករមានលក្ខណៈជាបរិមាណ**

  ឧទាហរណ៍ ÷ ចំនួនវ៉ាក់សាំងដែលបានផ្តល់, ចំនួនសិស្សដែលបានបង្រៀន, ចំនួនមុងដែលបានចែក

- **សូចនាករមានលក្ខណៈជាគុណភាព**

  ឧទាហរណ៍÷ រយៈពេលមធ្យមនៃការរងចាំរបស់អ្នកជំងឺក្នុងចន្លោះពេលទៅដល់ពេទ្យ និងពេលទទួលបានការព្យាបាល, រយៈពេលមធ្យមនៃការឆ្លើយតបរបស់អង្គភាពពន្លត់អគ្គិភ័យ, ការដាក់ពិន្ទុ (rating) លើភាពរាក់ទាក់សម្រាប់សេវាដែលបានផ្តល់, ភាគរយនៃអតិថិជនដែលយល់ឃើញថាបានទទួលសេវាតាមការរំពឹងទុក

- **សូចនាករប្រសិទ្ធភាព**

  ឧទាហរណ៍÷ ថ្លៃចំណាយក្នុងការផ្តល់វ៉ាក់សាំងមួយដង, ផលធៀបចំនួនមន្ត្រី និងចំនួនប្រជាជន (មន្ត្រីម្នាក់បម្រើប្រជាជនបានប៉ុន្មាននាក់?)

# ឧទាហរណ៍: ក្រសួងអប់រំ យុវជន និងកីឡា

## គោលបំណងគោលនយោបាយ

- ទី ១: ធានាលទ្ធភាពទទួលបាន សេវាអប់រំ ប្រកបដោយសមធម៌
- ទី ២: លើកកម្ពស់គុណភាព និងភាពឆ្លើយតប

## កម្មវិធី

១. ការអភិវឌ្ឍការអប់រំក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការ
២. ការអភិវឌ្ឍឧត្តមសិក្សា និងការស្រាវជ្រាវ
៣. ការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា
៤. ការអភិវឌ្ឍជំនាញបច្ចេកទេសនិងជំនាញទន់សម្រាប់យុវជន
៥. ការគាំទ្រសេវាអប់រំ និងអភិបាលកិច្ចល្អ

## អនុកម្មវិធី

១. ការពង្រីកការអប់រំកុមារតូច
២. ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅបឋមសិក្សា
៣. ការចូលរៀនប្រកបដោយសមធម៌ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅមធ្យមសិក្សា"
៤. ការពង្រីកការអប់រំក្រៅប្រព័ន្ធ
៥. ការពង្រឹង និងការពង្រីកកម្មវិធីលើកកម្ពស់សុខភាពសិក្សា
៦. លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីអប់រំបច្ចេកទេស
៧. ការអភិវឌ្ឍការងារបណ្ដុះបណ្ដាល និងរិក្រឹតការគ្រូបង្រៀន
៨. ការអភិវឌ្ឍកម្មវិធីសិក្សា សម្ភារៈសិក្សា និងបណ្ណាល័យ
៩. ការគាំទ្ររបស់មន្ទីរជំនាញរាជធានី ខេត្ត

# ឧទាហរណ៍: ក្រសួងអប់រំ យុវជន និងកីឡា (ត)

## សូចនាករ នៃអនុកម្មវិធីទី ២ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅបឋមសិក្សា

| សូចនាករលទ្ធផលក្នុងឆ្នាំ | គោលដៅឆ្នាំ ២០១៦ | គោលដៅឆ្នាំ ២០១៧ | គោលដៅឆ្នាំ ២០១៨ | សូចនាករលទ្ធផលចុងក្រោយ | គោលដៅ |
|---|---|---|---|---|---|
| អត្រាពិតចូលរៀនថ្មី | ៩៥,៣% | ៩៩,៤% | ១០០% | អត្រាបញ្ចប់ការសិក្សា | ១០០% |
| អត្រាពិតនៃការសិក្សា | ៩៨,២% | ៩៨,៩% | ៩៩% | | |
| អត្រាសិស្សឡើងថ្នាក់នៅបឋមសិក្សា | ៨៤,៧% | ៨៦,៥% | ៩៤% | | |
| ចំនួនសាលាអនុវត្តកម្មវិធីសិក្សាកុមារមេត្រី | ៧២,៤៧% | ៧៣,៦៣% | ៩០% | ភាគរយសាលាមេត្រីបានអនុវត្តកម្មវិធីសាលាកុមារមេត្រី | ១០០% |



កាត់បន្ថយភាពក្រីក្រ
កសិកម្ម
បង្កើនកសិផលឱ្យបាន ១០%
ផ្តល់បច្ចេកទេសកសិកម្ម
ផ្តល់ពូជស្រូវ
អ្នកគ្រប់គ្រងកម្មវិធី
កសិផលកើនបាន ១០%
កាត់បន្ថយភាពក្រីក្រ
អ្នកគ្រប់គ្រងកម្មវិធី

# ៣.៣.៤. ការគណនាថ្លៃចំណាយ

## សារៈសំខាន់នៃការគណនាថ្លៃចំណាយ

- ការគណនាគណនាថ្លៃចំណាយ មានសារៈសំខាន់ក្នុងការប្រៀបធៀបលទ្ធផលនៃកម្មវិធី ដែលរំពឹងទុក ធៀបទៅនឹងទំហំចំណាយក្នុងការបង្កើតលទ្ធផលនៃកម្មវិធីនោះ។
- ការប្រៀបធៀបនេះ នឹងជួយដល់ការធ្វើសេចក្តីសម្រេចចិត្តក្នុងការវិភាជធនធាន/ថវិកាប្រកបដោយប្រសិទ្ធភាព។



# ៣.៣.៤. ការគណនាថ្លៃចំណាយ (ត)

## តក្កនៃការគណនាថ្លៃចំណាយ

តើធ្លាប់បានអនុវត្តកម្មវិធីពីមុនឬទេ? → ធ្លាប់

↓

មិនធ្លាប់

- មានកម្មវិធីស្រដៀងគ្នា
- មិនមានកម្មវិធីស្រដៀងគ្នា

# Security Awareness Maturity Model






# ៣.៣.៤. ការគណនាថ្លៃចំណាយ (ត)

## វិធីសាស្ត្រគណនាថ្លៃចំណាយ

ការគណនាថ្លៃចំណាយត្រូវគិតគូចេញពីសកម្មភាពនៃចង្កោមសកម្មភាពនីមួយៗ

ឧទាហរណ៍

| សកម្មភាព: ការរៀបចំសារាចរណែនាំ ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំបន្ទាប់ | បរិមាណ | ថ្លៃឯកតា | សរុបទឹកប្រាក់ |
|---|---|---|---|
| ក្រដាស | | | |
| ទឹកថ្នាំម៉ាស៊ីនបោះពុម្ព | | | |
| ទឹកថ្នាំម៉ាស៊ីនហ្វូតូកូពី | | | |
| ប៊ិច | | | |
| ប្រដាប់កៀប (Binder Clip) | | | |
| Post it | | | |
| ....... | | | |

# ផែនការលម្អិត

| | | |
|---|---|---|
| រយៈពេល → | ~~១០ ឆ្នាំ~~ → | ៨ ឆ្នាំ |
| ចំណាយហិរញ្ញវត្ថុ → | ~~១០ ០០០ ០០០ រៀល~~ → | ៨ ០០០ ០០០ រៀល |
| ធនធានមនុស្ស → | ~~១០០ នាក់~~ → | ៨០ នាក់ |

**កត្តាជំរុញថ្លៃចំណាយ**

- ការផ្លាស់ប្តូរគោលនយោបាយរដ្ឋាភិបាល
- ការប្រែប្រួលសង្គមនិងសេដ្ឋកិច្ច
- ការរីកចម្រើនផ្នែកបច្ចេកវិទ្យា
- ការប្រែប្រួលប្រជាសាស្ត្រ
- បរិយាកាសខាងក្រៅ

# ៣.៥ ការតាមដាន ការធ្វើរបាយការណ៍ និងការវាយតម្លៃ

ការវាយតម្លៃ÷ គឺជាការត្រួតពិនិត្យឡើងវិញជាប្រចាំ ឬ តាមពេលកំណត់លើការអនុវត្តកម្មវិធី

ការតាមដាន ÷ គឺជាការប្រៀបធៀបលទ្ធផលនៃការអនុវត្តកម្មវិធីទៅនឹងការគ្រោងទុក ដើម្បីកែលម្អការរៀបចំថវិកានាឆ្នាំបន្ទាប់

ការធ្វើរបាយការណ៍÷ គឺជាការរាយការណ៍ព័ត៌មាន ឬ ទិន្នន័យអំពីការអនុវត្តថវិកា (ដោយបំពេញទម្រង់ដែលរៀបចំរួចជាស្រេច) ដើម្បីដាក់ជូនទៅប្រធានស្ថាប័នគ្រប់គ្រងជ្រាប។ ក្រសួងស្ថាប័នអនុវត្តថវិកាកម្មវិធី ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និង របាយការណ៍សមិទ្ធកម្ម តាមពេលវេលាកំណត់



# ៣.៥ ការតាមដាន ការធ្វើរបាយការណ៍ និងការវាយតម្លៃ

គឺជាការត្រួតពិនិត្យឡើងវិញជាប្រចាំ ឬ តាមពេលកំណត់លើការអនុវត្តកម្មវិធី

គឺជាការប្រៀបធៀបលទ្ធផលនៃការអនុវត្តកម្មវិធីទៅ
នឹងការគ្រោងទុក ដើម្បីកែលម្អការរៀបចំថវិកានាឆ្នាំបន្ទាប់

គឺជាការរាយការណ៍ព័ត៌មាន ឬ ទិន្នន័យអំពីការអនុវត្តថវិកា (ដោយបំពេញទម្រង់ដែលរៀបចំរួចជាស្រេច) ដើម្បីដាក់ជូនទៅប្រធានស្ថាប័នគ្រប់គ្រងជ្រាប។ ក្រសួង ស្ថាប័នអនុវត្តថវិកាកម្មវិធី ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សមិទ្ធកម្ម តាមពេលវេលាកំណត់



# ទស្សនវិជ្ជានៃវិធីសាស្ត្រថវិកាកម្មវិធី



មហិច្ឆតា និងការផ្លាស់ប្តូរជាបណ្តើរៗ
នូវប្រព័ន្ធគ្រប់គ្រងថវិការបស់កម្ពុជា
ឆ្ពោះទៅប្រព័ន្ធគ្រប់គ្រងថវិកាផ្តោតលើ
លទ្ធផល ឬ សមិទ្ធកម្ម និងវិមជ្ឈការ
ឱ្យបានជោគជ័យនៅឆ្នាំ២០២៥។

# ផ្នែកទី ៤. អង្គភាពថវិកា

# ៤.១. សេចក្តីផ្តើម

១

ការលើកកម្ពស់គណនេយ្យភាពហិរញ្ញវត្ថុ ជាចំណុចស្នូលនៅក្នុងជំហានទី ២ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

២

ការអនុវត្តក្របខណ្ឌអង្គភាពថវិកា នឹងធ្វើឱ្យការបែងចែកមុខងារ ភារកិច្ច និង ការទទួលខុសត្រូវ កាន់តែមានភាពច្បាស់លាស់រវាង អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ និងអង្គភាពជំនាញ ឬ អង្គភាពផ្តល់សេវាសាធារណៈ។

៣

ទន្ទឹមនឹងនេះ នឹងអាចបង្កើនគណនេយ្យភាពសមិទ្ធកម្ម និងប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិក្នុងការគ្រប់គ្រង និងការអនុវត្តសកម្មភាពការងាររបស់ក្រសួងស្ថាប័ន។

# ៤.២. ក្របខណ្ឌអង្គភាពថវិកា

## និយមន័យ



### អង្គភាពថវិកា

- ជាអង្គភាពស្ថិតក្នុងរចនាសម្ព័ន្ធក្រសួងស្ថាប័នដែលបានបង្កើតឡើងដោយរាជរដ្ឋាភិបាល
- ជាអង្គភាពដែលទទួលបានអាណត្តិកិច្ចច្បាស់លាស់ក្នុងការអនុវត្តសកម្មភាព ដើម្បីបង្កើតបានជាលទ្ធផលជាក់លាក់។

# ៤.២. ក្របខណ្ឌអន្តរភាពថវិកា (ត)

## ទំនាក់ទំនងរវាងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន និងរចនាសម្ព័ន្ធគោលនយោបាយ

| រចនាសម្ព័ន្ធគ្រប់គ្រង | សិទ្ធិអំណាច និងការទទួលខុសត្រូវ | រចនាសម្ព័ន្ធគោលនយោបាយ |
|---|---|---|
| កម្រិតដឹកនាំ និងកំណត់គោលនយោបាយ (កម្រិតទី១: ក្រសួងស្ថាប័ន) | កំណត់គោលនយោបាយ | គោលបំណងគោលនយោបាយ/ យុទ្ធសាស្ត្រ/កម្មវិធី |
| កម្រិតគ្រប់គ្រងបច្ចេកទេស និងកំណត់ យុទ្ធសាស្ត្រ/កម្មវិធី (កម្រិតទី២: អគ្គលេខាធិការ/អគ្គនាយកដ្ឋាន) | កំណត់យុទ្ធសាស្ត្រ/ កម្មវិធី | យុទ្ធសាស្ត្រ/កម្មវិធី |
| កម្រិតបច្ចេកទេស និងកំណត់ អនុកម្មវិធី/ ចង្កោមសកម្មភាព (កម្រិតទី៣: នាយកដ្ឋាន / សមមូល) | កំណត់អនុកម្មវិធី/ ចង្កោមសកម្មភាព | អនុកម្មវិធី/ ចង្កោមសកម្មភាព |
| កម្រិតបច្ចេកទេស និងអនុវត្តសកម្មភាព (កម្រិតទី៣/៤...: បណ្តាអង្គភាពក្រោមឱវាទ) | កំណត់/អនុវត្តសកម្មភាព | សកម្មភាព |



លទ្ធផលចុងក្រោយ

លទ្ធផលមធ្យម

លទ្ធផលបឋម

# ការទទួលខុសត្រូវ គណនេយ្យ

# ៤.២. ក្របខណ្ឌអនុភាពថវិកា (ត)

**លក្ខខណ្ឌវិនិច្ឆ័យ**

1 - ជាអង្គភាពរដ្ឋដែលទទួលបានថវិកាតាមរយៈប្រព័ន្ធថវិការដ្ឋ

2 - អង្គភាពស្ថិតក្នុងរចនាសម្ព័ន្ធ និងត្រូវកំណត់មុខងារនិងភារកិច្ច ព្រមទាំងមានបន្ទាត់គណនេយ្យភាពត្រឹមត្រូវ

3 - មានទំហំសមស្រប និងប្រកបដោយនិរន្តរភាព (ទំហំការងារ ទំហំតម្រូវការបុគ្គលិក និងទំហំតម្រូវការថវិកា)

4 - មានសមិទ្ធកម្ម ឬលទ្ធផលក្នុងឆ្នាំ និងចុងក្រោយ នៅក្នុងកម្រិតដែលអាចវាស់បាន

5 - មានសមត្ថភាពក្នុងការរៀបចំផែនការសកម្មភាពការងារ ផែនការយុទ្ធសាស្ត្រ និងថវិកាប្រចាំឆ្នាំ

6 - មានភាពជាម្ចាស់ក្នុងការគ្រប់គ្រងដឹកនាំ

7 - ការវិភាជថវិកាប្រចាំឆ្នាំ និងការទទួលខុសត្រូវក្នុងការអនុវត្តការងារ

# ៤.២. ក្របខណ្ឌអង្គភាពថវិកា (ត)

## ការទទួលខុសត្រូវរវាងអង្គភាពថវិកា និងអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ

| អង្គភាពថវិកា | អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ |
|---|---|
| ❖ ការរៀបចំ<br>- ចូលរួម និងសហការរៀបចំផែនការយុទ្ធសាស្ត្រថវិកា<br>- ចូលរួមរៀបចំផែនការថវិកាកម្មវិធីប្រចាំឆ្នាំ | ❖ ការរៀបចំ<br>- រៀបចំគោលការណ៍ និងនីតិវិធីផ្ទៃក្នុងសម្រាប់រៀបចំថវិកាកម្មវិធី<br>- រៀបចំ និងបូកសរុបផែនការយុទ្ធសាស្ត្រថវិកាថវិកាកម្មវិធីប្រចាំឆ្នាំ<br>- ត្រួតពិនិត្យគម្រោងថវិការបស់អង្គភាពថវិកា |
| ❖ ការអនុវត្ត<br>- គ្រប់គ្រង និងចាត់ចែងថវិកា និងធាតុចូលនានា<br>- រៀបចំកម្មវិធីចំណូល-ចំណាយរបស់អង្គភាព<br>- ត្រួតពិនិត្យ និងតាមដានការអនុវត្តផែនការសកម្មភាព<br>- ស្នើសុំចលនាឥណទាន ឬនិយ័តកម្មឥណទានថវិកាទៅអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ<br>- លើកសំណើសុំការទិញ និងសុំការធានាចំណាយផ្សេងៗ | ❖ ការអនុវត្ត<br>- រៀបចំគោលការណ៍ និងនីតិវិធីផ្ទៃក្នុងបន្ថែមសម្រាប់អនុវត្តថវិកា<br>- រៀបចំកម្មវិធីចំណូល-ចំណាយសាច់ប្រាក់ប្រចាំត្រីមាស<br>- គាំទ្រនិងសម្របសម្រួលជាមួយអង្គភាពថវិកាក្នុងការគ្រប់គ្រងថវិកា |

# ៤.២. ក្របខណ្ឌអង្គភាពថវិកា (ត)

## ការទទួលខុសត្រូវរវាងអង្គភាពថវិកា និងអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ

| អង្គភាពថវិកា | អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ |
|---|---|
| ❖ ការពិនិត្យ និង ការតាមដានការអនុវត្តថវិកា<br>- ពិនិត្យតាមដានជាប្រចាំនូវការអនុវត្តថវិកា និងការអនុវត្តសកម្មភាពការងារ<br>- រៀបចំរបាយការណ៍ស្តីពីការអនុវត្តថវិកា និងលទ្ធផលសកម្មភាពការងារ | ❖ ការពិនិត្យ និង ការតាមដានការអនុវត្តថវិកា<br>- គ្រប់គ្រង ពិនិត្យ និង តាមដានការអនុវត្តថវិកាកម្មវិធី<br>- សហការជាមួយអង្គភាពសវនកម្មផ្ទៃក្នុងរបស់ក្រសួងស្ថាប័នសាមី<br>- រៀបចំប្រព័ន្ធរបាយការណ៍ផ្ទៃក្នុង<br>- ពិនិត្យតាមដានការអនុវត្តថវិការបស់គ្រប់អង្គភាពថវិកា<br>- រៀបចំ និងបូកសរុបរបាយការណ៍អនុវត្តថវិការបស់អង្គភាពថវិកា |
| ❖ ការចាត់តាំងមន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុ<br>- អង្គភាពថវិកាត្រូវចាត់តាំងមន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុ | |

# ៤.៣. នីតិវិធីក្នុងការរៀបចំអង្គភាពថវិកា

**ជំហានទី១**
ការពិនិត្យលើបេសកកម្ម អាណត្តិកិច្ច និង គោលបំណងគោល-នយោបាយ

**ជំហានទី២**
ការពិនិត្យលើ រចនាសម្ព័ន្ធគ្រប់គ្រង ស្ថាប័ន បច្ចុប្បន្ន

**ជំហានទី៣**
ការពិនិត្យនិងវាយតម្លៃ លើអង្គភាពដែលអាច ក្លាយជាអង្គភាពថវិកា

**ជំហានទី៤**
ការរៀបចំបង្កើត អង្គភាពថវិកា

**ជំហានទី៥**
ការរៀបចំ និងអនុម័ត លើរបាយការណ៍ស្តីពី ការរៀបចំអង្គភាពថវិកា

**ជំហានទី៦**
ការត្រួតពិនិត្យ និង ឯកភាពលើសំណើ បង្កើតអង្គភាពថវិកា

# ៤.៤. ក្របខណ្ឌអន្តរភាពថវិកា (ត)

## អត្ថប្រយោជន៍

1

អនុញ្ញាតឱ្យមានការរៀបចំ និងវិភាជថវិកាកាន់តែប្រសិទ្ធភាព ពិសេសការផ្សារភ្ជាប់ថវិកាទៅនឹងលទ្ធផលកាន់តែប្រសើរជាងមុន

2

ជំរុញឱ្យមានប្រព័ន្ធត្រួតពិនិត្យ ផ្ទៃក្នុងច្បាស់លាស់ ពិសេស ងាយស្រួលដល់ការរៀបចំ យន្តការត្រួតពិនិត្យការអនុវត្តថវិកា លទ្ធផលសកម្មភាពការងារ និងសមិទ្ធកម្មបានកាន់តែប្រសើរជាងមុន

3

អនុញ្ញាតឱ្យមានការបែងចែកមុខងារ និងការទទួលខុសត្រូវកាន់តែច្បាស់លាស់រវាងអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ (អ្នកវិភាជ និងតាមដានការគ្រប់គ្រងថវិកា) និងអង្គភាពជំនាញ ឬអង្គភាពផ្តត់ផ្គង់សេវាសាធារណៈ (អ្នកប្រើប្រាស់ និងគ្រប់គ្រងថវិការបស់ខ្លួន)

មហិច្ឆតា និងការផ្លាស់ប្ដូរជាបណ្ដើរៗ នូវប្រព័ន្ធគ្រប់គ្រងថវិការបស់កម្ពុជា ឆ្ពោះទៅប្រព័ន្ធគ្រប់គ្រងថវិកាផ្ដោតលើលទ្ធផល ឬ សមិទ្ធកម្ម និងវិមជ្ឈការ ឱ្យបានជោគជ័យនៅឆ្នាំ២០២៥។

# ផ្នែកទី ៥. នីតិវិធីអនុវត្តថវិកាចរន្តតាមកម្មវិធី

# ៥.១. ទស្សនៈរួមនៃការអនុវត្តថវិកា

- ផ្អែកលើមូលដ្ឋាននៃការរៀបចំថវិកា
- ធានាថវិកាត្រូវបានអនុវត្តដោយអនុលោមតាមច្បាប់
- សម្របតាមការប្រែប្រួលនៃបរិយាកាសម៉ាក្រូសេដ្ឋកិច្ច
- សមត្ថភាពដោះស្រាយតម្រូវការ និងបញ្ហាក្នុងពេលអនុវត្ត
- គ្រប់គ្រងប្រកបដោយប្រសិទ្ធភាព ភាពស័ក្តិសិទ្ធិ សន្សំសំចៃ
- សមត្ថភាពស្ថាប័ន HRM ព័ត៌មានវិទ្យា ការលើកទឹកចិត្ត
- ប្រព័ន្ធសវនកម្ម អធិការកិច្ច និងគណនេយ្យភាពគ្រប់គ្រង

# ៥.២. បរិបទ និងនីតិវិធីចំណាយថវិកាទូទៅ

➢ *បរិបទចំណាយថវិកាត្រូវបានបែងចែកជា៤ដំណាក់កាល÷*

- ដំណាក់កាលបែងចែកឥណទានថវិកាជូនក្រសួង ស្ថាប័ន និង អង្គភាពថវិកាក្រោមឱវាទ
- ដំណាក់កាលធានាចំណាយ ៖ គឺជាការសន្សារក្សាឥណទានថវិកាទុកទូទាត់ក្រោយពេលការងារ ឬគម្រោងត្រូវបំពេញរួចរាល់តាមគោលការណ៍ បទប្បញ្ញត្តិច្បាប់ និងនីតិវិធីហិរញ្ញវត្ថុជាធរមាន
- ដំណាក់កាលអនុវត្តកិច្ចលទ្ធកម្មសាធារណៈ
- ដំណាក់កាលទូទាត់

# ៥.២. បរិបទ និងនីតិវិធីចំណាយថវិកាទូទៅ (ត)

## បរិបទ នៃការអនុវត្ត ថវិកាកម្មវិធី

**ឥណទាន និងចលនា**

- ឥណទាន (រដ្ឋបាល, សេដ្ឋកិច្ចនិងកម្មវិធី)
- កញ្ចប់លទ្ធកម្ម, រដ្ឋទេយ្យ និង ផ្សេងៗ
- មូលដ្ឋានលើការចរចាថវិកា
- ចលនានៅត្រីមាសទី២

**ការធានាចំណាយ**

- កិច្ចលទ្ធកម្មសាធារណៈ
- ធានាចំណាយព្រម
    - បន្ទុកបុគ្គលិក
    - រដ្ឋទេយ្យបុរេប្រទាន
    - ក្រៅបន្ទុកបុគ្គលិក
- ធានាចំណាយមុន
    - បន្ទុកបុគ្គលិក
    - ក្រៅបន្ទុកបុគ្គលិក
    - បុរេប្រទាន

**ការទូទាត់**

- ទិដ្ឋាការអាណត្តិបើកប្រាក់
- ទូទាត់បើកផ្តល់ និងកិច្ចបញ្ជិកា

# ៥.៣. បរិបទចំណាយថវិការបស់អង្គភាពថវិកាដែលជាអាណាប័កផ្ទេរសិទ្ធិ (ត)



# ៥.៤. បរិបទចំណាយថវិការបស់អង្គភាពថវិកាដែល**មិនមែន**ជាអាណាប័កផ្ទេរសិទ្ធិ



# ៥.៥. សំណើចំណាយថវិកា

**សំណើ ចំណាយ ថវិកា**

- ឥណទាន កម្មវិធី ចំណូល ចំណាយ ផែនការលទ្ធកម្ម
- ជំពូក គណនី អនុគណនី
- កម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព លទ្ធផល
- បរិមាណ គុណភាព ប្រភេទ ប្រភព គោលរបប តម្លៃ...
- ពេលវេលាអនុវត្ត សកម្មភាពការងារ

# សូមអរគុណ

## សំណួរ និង ចម្លើយ

មហិច្ឆតា និងការផ្លាស់ប្តូរជាបណ្តើរៗ
នូវប្រព័ន្ធគ្រប់គ្រងថវិការបស់កម្ពុជា
ឆ្ពោះទៅប្រព័ន្ធគ្រប់គ្រងថវិកាផ្តោតលើ
លទ្ធផល ឬ សមិទ្ធកម្ម និងវិមជ្ឈការ
ឱ្យបានជោគជ័យនៅឆ្នាំ២០២៥។